## ទំព័រទី១៖ ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣២

# ឈើផ្សារភ្ជាប់នឹងវប្បធម៌ជប៉ុន

ទំព័រទី២៖

ទស្សនាវដ្ដីលេខ៣២នេះ និយាយអំពី "**ឈើផ្សារភ្ជាប់នឹងវប្បធម៌ជប៉ុន**"

នៅប្រទេសជប៉ុន ៧០%នៃផ្ទៃដី គ្របដណ្ដប់ដោយព្រៃឈើ ហើយដើមឈើគឺជាផ្នែកសំខាន់មួយនៃជីវិតប្រចាំថ្ងៃ។ ជំនាញបច្ចេកទេស និងគតិបណ្ឌិតរបស់បុព្វបុរសដែលគោរពធម្មជាតិដ៏ជ្រាលជ្រៅ និងបានប្រើប្រាស់អំណោយផលនៃព្រៃឈើយ៉ាងសំបូរបែប នៅតែបន្តមានក្នុងជីវភាពរស់នៅរបស់យើងសព្វថ្ងៃ។

ទំព័រទី៣៖ មាតិកា

- ស្ថាបត្យកម្មឈើដ៏គួរឱ្យចាប់អារម្មណ៍បំផុត
- បច្ចេកទេសសំណង់ប្រពៃណីដែលបានឆ្លងកាត់តាមសម័យកាល
- ឈើដែលបង្កើតការសម្រាកលំហែដ៏ល្អបំផុត
- សិប្បកម្មឈើលាយបញ្ចូលគ្នារវាងសហសម័យ និងប្រពៃណី
- ស្វែងយល់ពីក្លិនឈើ
- ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ ដើមឈើជាមួយរឿងរ៉ាវនានា
- រសជាតិជប៉ុន៖ ពេលវេលាទទួលទាន! ផ្សិតម៉ាត្សឺតាកិ
- ដើរកំសាន្តប្រទេសជប៉ុន៖ ម៉ាត្សឺម៉ុតុ
- វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖ កន្ត្រកឫស្សី

*រូបគំនូរដើមសាគូរ៉ាគូរដោយ សាកាអុិ ហុអុិស៊ឺ (១៧៦១–១៨២៩) ជាវិចិត្រករសម័យអេដុ* "Sakura Kaedezu Ryofu"

*រូបថតនៅគម្រប៖ សារមន្ទីរស្ថានឈើយ៉ឺស៊ីហារ៉ា ខេត្តកុឈិ ។ រូបថត៖* ©Takumi Ota

និប៉ុនិកា ត្រូវបានបោះពុម្ពជាភាសាជប៉ុន និងប្រាំមួយភាសាផ្សេងទៀត រួមមានភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ដើម្បីណែនាំទៅកាន់ពិភពលោកអំពីប្រជាជន និងវប្បធម៌ជប៉ុនសព្វថ្ងៃនេះ។

ចំណងជើងទស្សនាវដ្ដី និប៉ុនិកា មានប្រភពមកពីពាក្យ "និប៉ុន" ពាក្យជប៉ុន ដែលមានន័យថា ប្រទេសជប៉ុន។

*ទស្សនាវដ្ដីលេខ៣២ R-040314*

*បោះពុម្ពដោយក្រសួងការបរទេសនៃប្រទេសជប៉ុន*

*២-២-១ កាស៊ឹមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*

*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/

ទំព័រទី៤៖

## ស្ថាបត្យកម្មឈើដ៏គួរឱ្យចាប់អារម្មណ៍បំផុត

រាប់រយ ឬ រាប់ពាន់ឆ្នាំមកនេះ គ្រប់ជំនាន់បានថែរក្សាប្រាសាទ និងព្រះវិហាររបស់ជប៉ុន។ ការជួសជុល និងសាងសង់ឡើងវិញ ដើម្បីរក្សាភាពរុងរឿងនៃអតីតកាល ហើយភាពស្រស់ស្អាតនៃសំណង់ឈើទាំងនេះផ្តល់ឱ្យអ្នកទស្សនានូវបទពិសោធន៍ដ៏អស្ចារ្យ។

**ប៊្យូដូអ៊ីនហូអូដូ (ព្រះវិហារហង្សភ្លើងប៊្យូដូអ៊ីន)**

រូបខាងលើ៖ ព្រះវិហារនេះត្រូវបានសាងសង់ក្នុងសតវត្សទី១១ ក្នុងខេត្តក្យូតូ ហើយត្រូវបានជួសជុលឡើងវិញពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ដែលធ្វើឱ្យពណ៌ដ៏រស់រវើកមានឡើងវិញដូចពេលសាងសង់ដំបូង។ (រូបថតដោយ ប៊្យូដូអ៊ីន)

ទំព័រទី៥៖

**វិហារប្រាំជាន់ក្នុងវត្តរីរិកុជិ**

រូបស្តាំផ្នែកខាងលើ៖ វិហារប្រាំជាន់ដែលមានកំពស់ប្រហែល៣១ម៉ែត្រ សាងសង់ក្នុងសតវត្សទី១៥ ក្នុងវត្តរីរិកុជិ ខេត្តយ៉ាម៉ាហ្គុឈិ។ ដំបូលវិហារយ៉ាងធំប្រក់ដោយបន្ទះឈើ(សូមមើលទំព័រទី៨) បានបង្ហាញរូបរាងឆើតឆាយដ៏ប្រណិត។ (រូបថតដោយ PIXTA)

**ព្រះវិហារព្រះពុទ្ធរូបធំក្នុងវត្តតុដៃជិ**

រូបស្តាំផ្នែកខាងក្រោម៖ ព្រះវិហារព្រះពុទ្ធរូបធំក្នុងវត្តតុដៃជិ ខេត្តណារ៉ា គឺជាសំណង់ឈើប្រពៃណីដ៏ធំបំផុតមួយក្នុងពិភពលោក ដែលមានទំហំផ្នែកខាងមុខប្រហែល៥៧ម៉ែត្រ ជម្រៅប្រហែល៥០ម៉ែត្រ និងកម្ពស់ប្រហែល

៤៧ ម៉ែត្រ។ ផ្នែកខាងមុខរបស់ព្រះវិហារត្រូវបានគេនិយាយថាប្រហែល៨៦ម៉ែត្រ កាលពីពេលសាងសង់ដំបូងនៅក្នុងសតវត្សទី៨។ (*រូបថតដោយ* PIXTA)

<u>ទំព័រទី៦</u>៖

## បច្ចេកទេសសំណង់ប្រពៃណីដែលបានឆ្លងកាត់តាមសម័យកាល

ស្នាដៃរបស់សិប្បករដែលរក្សាបច្ចេកទេសសាងសង់បែបបុរាណ គឺជាបេះដូងនៃវប្បធម៌ស្ថាបត្យកម្មឈើនៅក្នុងប្រទេសជប៉ុន។ នៅទីនេះ យើងសូមណែនាំបច្ចេកទេសដ៏វិចិត្រទាំងនេះ ដែលត្រូវបានចុះបញ្ជីអង្គការយូណេស្កូជាបេតិកភណ្ឌវប្បធម៌អរូបី។

*រូបថត៖ កាវ៉ាបិ អាគិណុបឺ*

*១. វត្តស៊ិតេនណុជិ គឺជាវត្តដំបូងគេដែលត្រូវបានសាងសង់ដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។ កុនហ្គុ ហ៊្គឺមិ ដែលជាក្រុមហ៊ុនសិប្បកម្មឈើមួយ បានចូលរួមក្នុងការស្ថាបនាឡើងវិញនៅដើមសតវត្សទី២០។ (រូបថតដោយ PIXTA)*

*២. លោក គិអ៊ីឈិ ស៊ិហ្គិអុ(ឆ្វេង)ជាមេជាង និងលោក តុណិ កេនអ៊ិឈិ ជាប្រធានក្រុមហ៊ុនសិប្បកម្មឈើ កុនហ្គុ ហ៊្គឺមិ។ ទង់ដែលត្រូវបានគេហៅថា "បានស្ស៊ូគិ" ត្រូវបានសរសេរថា "ណាមឹ អាមិដាប៊ឹត្សឹ (ធម៌ព្រះពុទ្ធ)" ដែលមានបង្ហាញរូបនៃឧបករណ៍របស់ជាងឈើ ដូចជាប្រដាប់ឈូសឈើ ដែកដាប់ឈើ និងរណាជាដើមលើតួអក្សរនោះ។*

*៣. កានណា (ប្រដាប់ឈូសឈើ) ប្រើសម្រាប់ឈូសផ្ទៃឈើ។*

*៤. ប្រើ ណុមិ (ដែកដាប់)បន្តិចម្តងៗ ដើម្បីបានរូបរាងឈើជារាងកោង។ ដំណើរការទាំងអស់ត្រូវបានធ្វើដោយដៃ។*

*៥. ឧបករណ៍ជាងឈើរបស់លោកគីអ៊ីឈិ។ លោកមានឧបករណ៍ជាច្រើនដូចជា កានណា(ប្រដាប់ឈូសឈើ) ណុមិ(ដែកដាប់) និងកាណាហ្ស៊ឺឈិ (ញញួរ) សម្រាប់ប្រើប្រាស់ទៅតាមមុខងាររបស់វា។*

<u>ទំព័រទី៧</u>៖

*៦. ខាងលើ៖ លោក គិអ៊ីឈិ ប្រើបំណែកឈើគំរូ ដើម្បីពន្យល់ពីការភ្ជាប់ឈើហៅថា ត្ស៊ឹហ្គិតិ។*

*ខាងក្រោម៖ ដុំឈើម្ខាងស្រួចចុង ត្រូវបានដាក់ស៊កភ្ជាប់នឹងដុំឈើម្ខាងទៀតដែលឈូសឱ្យស៊ីគ្នាយ៉ាងសមល្អម។*

*៧. វិធីសាស្ត្រនៃការភ្ជាប់ឈើរាងធ្នឹម និងសសរ។ ការផ្គុំកំណាត់ឈើនៃផ្ទៃមុំ និងជ្រុងនីមួយៗទៅតាមទំហំយ៉ាងម៉ត់ចត់ បង្កើតបានជាសំណង់ដ៏រឹងមាំមួយ។*

**ជំនាញជាងឈើដែលមានប្រវត្តិ១៤០០ឆ្នាំ**

នៅប្រទេសជប៉ុន ព្រះវិហារ និងវត្តអារាម ត្រូវបានសាងសង់ និងជួសជុលឡើងវិញដោយក្រុមសិប្បករជំនាញហៅថា"មិយ៉ាដៃគឺ"។ ក្រុមហ៊ុនសិប្បកម្មឈើ កុនហ្គុ ហ៊្គុមិ ដែលមានទីតាំងនៅទីក្រុងអូសាកា គឺជាក្រុមហ៊ុនឈានមុខគេមួយរបស់ប្រទេសជប៉ុនដែលមានក្រុមសិប្បករជំនាញ(មិយ៉ាដៃគឺ)។ ក្រុមហ៊ុននេះត្រូវបានគេជឿថាមានប្រភពពីការសាងសង់វត្តស៊ិតែនណុជិ ដែលត្រូវបានសាងសង់ក្នុងឆ្នាំ៥៩៣ ហើយត្រូវបានគេស្គាល់ថាជាក្រុមហ៊ុនសិប្បកម្មឈើចំណាស់ជាងគេបំផុតនៅក្នុងពិភពលោក។

លោក គិអ៊ីឈិ ស៊ិហ្គិអុ នៃក្រុមហ៊ុនសិប្បកម្មឈើ កុនហ្គុ ហ៊្គុមិ គឺជាជាងឈើជើងចាស់ដែលមានអាជីពជាង៥០ឆ្នាំ។ ក្នុងនាមជាតូវ៉្យូ ឬមេជាង គាត់ត្រូវមើលការខុសត្រូវជាងឈើវ័យក្មេង។ គាត់យកឈើទៅឈូស ដោយប្រើកានណា (ប្រដាប់ឈូសឈើ) ឈូសចេញជាសាច់ឈើដូចខ្សែបូស្តើងៗ។ បច្ចេកទេសឈូសឈើរបស់លោកបានបង្កើតសាច់ឈើដែលស្តើងជាងក្រដាសទៅទៀត ដែលវាជាលទ្ធផលនៃការហ្វឹកហាត់ជាច្រើនឆ្នាំរបស់គាត់។

បច្ចេកទេសប្រពៃណីដ៏សំខាន់បំផុតមួយក្នុងការសាងសង់ព្រះវិហារ និងវត្តអារាម ត្រូវបានគេហៅថា "គិហ៊្គុមិ" ដែលជាវិធីសាស្រ្តនៃការភ្ជាប់ឈើដោយមិនប្រើដែកគោល ឬដែកភ្ជាប់ នោះទេ។ វិធីសាស្រ្តគិហ៊្គុមិ គឺរក្សាសាច់ឈើមិនឱ្យងាយរងការខូចខាតដែលបណ្តាលមកពីលោហៈធាតុច្រេះ ហើយការភ្ជាប់ឈើទាំងនេះក៏បានស្រូបយក និងបំបែកកម្លាំងនៃរំញ័រ ដែលវាមានប្រសិទ្ធភាពទប់ទល់នឹងការរញ្ជួយដីផងដែរ។

លោក គិអ៊ីឈិ ពន្យល់ថា "បច្ចេកទេសរបស់គិហ៊្គុមិ សំខាន់គឺការភ្ជាប់ឈើហៅថា "ត្ស៊ុហ្គិតិ" ដែលភ្ជាប់ ឬ តឈើបង្កើតបានជាសសរវែង ឬ ធ្នឹម និងការភ្ជាប់ឈើមួយទៀតហៅថា "ស៊ិហ៊្គុឈិ" ដែលភ្ជាប់ ឬ ផ្គុំសសរ និងធ្នឹមជាមុំមួយ។ បច្ចេកទេសរបស់គិហ៊្គុឈិ មានច្រើនជាង២០០របៀបដែលអាចយកមកប្រើប្រាស់បាន ដោយអាស្រ័យលើភាពរឹងមាំនៃឈើ និងការរចនានៃអគារ។

ក្រុមសិប្បករជំនាញ(មិយ៉ាដៃគឺ) មិនត្រឹមតែមានចំណេះដឹងពេញលេញអំពីលក្ខណៈនៃឈើប៉ុណ្ណោះទេ ប៉ុន្តែក៏មានការយល់ដឹងយ៉ាងស៊ីជម្រៅអំពីបច្ចេកទេសកាត់ឈើ និងវប្បធម៌ជប៉ុនផងដែរ។ នេះជាមូលហេតុដែលត្រូវចំណាយពេលជាង១០ឆ្នាំដើម្បីក្លាយជាជាងឈើពេញលក្ខណៈ។

ជាមួយនឹងចំនួនយុវជនដែលប្រាថ្នាចង់ក្លាយជា មិយ៉ាដៃគឺ បានធ្លាក់ចុះក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលការបណ្តុះបណ្តាលជាងឈើជំនាន់ក្រោយបានក្លាយទៅជាបញ្ហាប្រឈមដ៏សំខាន់មួយ។ ទោះជាយ៉ាងណាក៏ដោយ ការដោះ

ស្រាយបញ្ហានេះ ដូចដែលលោក តុណិ គេនអ៊ិឈិ ប្រធានក្រុមហ៊ុនសិប្បកម្មឈើ កុនហ្គុ ហ៊្គឹមិ មានប្រសាសន៍ថា "វាមិនមែនត្រឹមតែបញ្ហានៃបច្ចេកទេសបង្រៀននោះទេ។"

"ព្រះ ឬ អាទិទេព គង់នៅសំណាង់ដែលត្រូវបានប្រជាជនក្នុងសហគមន៍គោរពបូជា។ ក្រុមមិយ៉ាដៃគឺ ក៏ត្រូវតែយល់ពីអារម្មណ៍ដែលប្រជាជនលះបង់ចំពោះព្រះវិហារ និងវត្តអារាមទាំងនោះផងដែរ"។

<u>ទំព័រទី៨៖</u>

*១. ដំបូលបែបហ៊ិវ៉ាដាប៊ឺគិ នៃព្រះវិហារគឺម៉ាណុ ហុនហ្គុឹ តៃស្យ៉ា។ (រូបថត៖ PIXTA)*

*២. ម៉ុតុកាវ៉ាស៊ិ (អ្នកឯកទេសប្រមូលសំបកឈើ) ឡើងដើមឈើដែលមានកំពស់ជាង១០ម៉ែត្រ ដើម្បីប្រមូលសំបកដើមឈើ។*

*៣. កាំបិតពិសេសមួយត្រូវបានប្រើដើម្បីជ្រៀកសំបកឈើដើមស្រល់ហ៊ិណុគិ។*

*៤. សំបកដើមស្រល់ដែលត្រាំទឹកហើយ យកមកតម្រៀបជាជួរ។*

*៥. បច្ចេកទេសប្រក់ដំបូលមានការប្រែប្រួលអាស្រ័យលើផ្នែកផ្សេងៗគ្នានៃដំបូល បង្កើតជាគ្រោងដំបូល យ៉ាងអស្ចារ្យ (រូបថត២–៥ ផ្ដល់ដោយ៖ សហគមន៍សម្រាប់ការថែរក្សាបច្ចេកទេសដំបូលប្រាសាទ និងវត្តអារាម)*

**ដំបូលប្រកបដោយសិល្បៈធ្វើពីស្រទាប់សំបកឈើ**

ស្ថាបត្យកម្មបែបប្រពៃណីជប៉ុន ប្រើវិធីសាស្ត្រប្រក់ដំបូលជាច្រើន រួមទាំងក្បឿងសេរ៉ាមិច ដើមត្រែង(ស៊ឺស៊ឺគិ) ឬដើមស្មៅយ៉ុស៊ិ និងបន្ទះក្ដារដើមតាត្រៅ(ស៊ឹហ្គិ) និងដើមស្រល់សាវ៉ារ៉ាជាដើម។ ក្នុងចំណោមនោះ ដំបូលបែបហ៊ិវ៉ាដាប៊ឺគិ ធ្វើពីស្រទាប់សំបកឈើដើមស្រល់ហ៊ិណុគិ ដែលជាបច្ចេកទេសដ៏គួរឱ្យកត់សម្គាល់តែមួយគត់របស់ប្រទេសជប៉ុន។

សម្រាប់បច្ចេកទេសនេះ សំបកដើមស្រល់ហ៊ិណុគិជប៉ុនដែលមានអាយុជិត១០០ឆ្នាំត្រូវបានយកមកប្រើប្រាស់។ សំបកឈើត្រូវបានប្រមូលដោយអ្នកឯកទេសហៅថា "ម៉ុតុកាវ៉ាស៊ិ" ដោយដាក់ដែកគាស់សំបកចាប់ពីគល់ទៅហើយចាប់ទាញបកសំបកឈើនោះចេញពីក្រោមទៅដល់កំពូលដើមឈើ។ បច្ចេកទេសនេះត្រូវបានធ្វើដោយមិនធ្វើឱ្យខូចទៅដល់សំបកខាងក្នុងឈើទេ ដូច្នេះសំបកខាងក្រៅនឹងដុះឡើងវិញក្នុងរយៈពេលប្រហែលដប់ឆ្នាំ ហើយអាចប្រមូលបានម្ដងទៀត។

ពេលប្រមូលសំបកឈើហើយ សិប្បករកាត់សំបកឈើនោះដោយបណ្ដោយប្រវែង ៧៥ស.ម ទទឹង១៥ស.ម ហើយដាក់ផ្ដេកវាម្ដងមួយៗតម្រៀបគ្នា។ សំបកឈើនោះត្រូវបានដាក់គរជាស្រទាប់ៗចន្លោះ១.២ស.ម ហើយ

គៀបនៅបង្គោលឬស្សីរៀងរាល់ប្រាំស្រទាប់។ ភាពខ្វាត់ខ្វែងនៃស្រទាប់ដ៏ស្មុគ្រស្មាញនៅទីបំផុតបង្កើតបានជាដំបូលដែលមានរាងកោង ក្រាស់ និងរឹងមាំ។

បច្ចេកទេសសាងសង់ប្រកបដោយនិរន្តរភាពដោយប្រើវត្ថុធាតុដើមពីធម្មជាតិ ត្រូវបានមើលឃើញពីតម្លៃ និងទទួលស្គាល់សាជាថ្មីក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។

**បច្ចេកទេសលាបពណ៌ដែលបង្កើតឡើងវិញនូវរូបរាងអតីតកាល**

ការលាបពណ៌ចម្លាក់ និងគំនូរស្ថាបត្យកម្ម គឺជាធាតុផ្សំដ៏សំខាន់ក្នុងការស្តារឡើងវិញនូវអគារព្រះវិហារ និងវត្តអារាម។ គោលបំណង គឺដើម្បីបង្កើតរូបរាងដើមនៃអគារឡើងវិញ។ ជាដំបូង គេត្រូវវិភាគស្ថានភាព បន្ទាប់មកត្រួត ពិនិត្យបច្ចេកទេស។ ការ ម្រ័ក្សណ៍ខ្មុក សារធាតុពណ៌ពីសារធាតុរ៉ែ និងសារធាតុពណ៌ធម្មជាតិផ្សេងទៀតដែលប្រើក្នុងគំនូរជប៉ុន ដែលត្រូវបានគេប្រើដើម្បីបំពេញបំណះលាបពណ៌ និងស្តារការរចនាឱ្យដូចដើមវិញ។ ការលាបពណ៌ក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការងារជួសជុលឡើងវិញទាក់ទងនឹងការការពារឈើផងដែរ។

*៦. ខ្លោងទ្វារ ការ៉ាម៉ុន នៃវត្តនិស៊ិ ហុនហ្គាជិត្រូវបានគេស្គាល់ថាជាចម្លាក់ដ៏អស្ចារ្យ។ នៅឆ្នាំ២០១៨ ខែមិថុនា វាត្រូវបានជុសជុលឡើងវិញដោយចំណាយពេល ៣ឆ្នាំ ៩ខែ ក្រោយពីខានជួសជុលប្រហែល៥០ឆ្នាំ (រូបថតផ្តល់ដោយៈ ពីវត្តនិស៊ិ ហុនហ្គាជិ)*

*៧. សិប្បករម្នាក់ជួសជុលចម្លាក់ទ្វារ។ ដើម្បីកំណត់អត្តសញ្ញាណសារធាតុពណ៌ដែលប្រើនៅពេលសាងសង់ខ្លោងទ្វារដំបូង គេបានធ្វើការវិភាគកាំរស្មីអ៊ិច* (fluorescent) *ការស្រាវជ្រាវបណ្ណសារ និងឧបករណ៍ផ្សេងទៀត។ (រូបថតផ្តល់ដោយៈ វិទ្យាស្ថានស្រាវជ្រាវសិល្បៈការ៉ាម៉ុ)*

**រនាំងស្អាត និងរឹងមាំ ដែលប្រើបច្ចេកទេសសិប្បកម្មឈើដ៏វិចិត្រ**

នៅក្នុងស្ថាបត្យកម្មជប៉ុនបុរាណ គ្រឿងបរិក្ខារបញ្ឈរហៅថា "តាតិហ្គុ" ដូចជាទ្វារ និងបង្អួចត្រូវបានចាត់ទុកថាសំខាន់ដូចការសាងសង់អគារទាំងមូលដែរ។ បច្ចេកទេសកែច្នៃឈើដ៏ប្រណិត ដោយប្រើឈើស្តើង និងស្រាល គឺមិនអាចខ្វះបានក្នុងការផលិតគ្រឿងបរិក្ខារដែល ងាយស្រួលប្រើ ប្រើប្រាស់បានយូរ និងរឹងមាំគ្រប់គ្រាន់ដើម្បីទប់ទល់នឹងការបើក និងបិទញឹកញាប់ជារៀងរាល់ថ្ងៃ។ ដើម្បីការពារការប្រេះ ការខូចរូបរាង និងប្រើបានរាប់រយឆ្នាំ គឺមានតែឈើល្អដែលមានទទឹងរង្វង់ និងក្រយៅឈើតូចប៉ុណ្ណោះដែលត្រូវបានជ្រើសរើសយកមកផ្គុំធ្វើជាតាតិហ្គុ ដែលប្រភេទឈើទាំងនោះមាន ហ៊ិណុគិ(ដើមស្រល់ហ៊ិណុគិ) ស៊ីហ្គិ(ដើមតាត្រៅ) ម៉ាត្ស៊ឺ (ដើមស្រល់ម៉ាត្ស៊ឺ) និង កិយ៉ាគិ (ដើមហ្សេលកូវ៉ា) ជាដើម។

*៨. តាតិហ្គុ (ប្រភេទបង្អួច) មានឈ្មោះថា "ស៊ិតុមិដុ" ត្រូវបានធ្វើឡើងនៅក្នុងវត្តដៃហុអុនជិ ដែលត្រូវបានសាងសង់ប្រហែល៨០០ឆ្នាំមុន (ផ្នែកខាងឆ្វេងនៃរូបថត) ។ (រូបថតដោយៈ* Aflo)

*៩. លោក ស៊ីហ្សឺគិ តាដាស៊ិ សិប្បករជាងឈើធ្វើតាតិហ្គឺ ឈានមុខគេ ក្នុងការផលិត និងជួសជុលឧបករណ៍ប្រពៃណីអស់រយៈពេលជាង៦០ឆ្នាំមកហើយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ លោកបានផ្តោតការយកចិត្តទុកដាក់លើការផ្ទេរជំនាញរបស់ខ្លួនដល់ជាងឈើវ័យក្មេង។ (រូបថតផ្តល់ដោយ៖ សហគមន៍អភិរក្សបច្ចេកទេសសិប្បកម្មបុរាណ)*

*១០. គ្រោងបង្អួចរាងការ៉េ ដើម្បីធ្វើ ស៊ិគុមិដុ។ រចនាសម្ព័ន្ធគ្រោងឈើធ្វើពីបន្ទះឈើពិតជាល្អប្រណិត។ (រូបថតផ្តល់ដោយ៖ សហគមន៍អភិរក្សបច្ចេកទេសសិប្បកម្មបុរាណ)*

<u>ទំព័រទី១០៖</u>

## ឈើដែលបង្កើតការសម្រាកលំហែដ៏ល្អបំផុត

រថភ្លើងដំណើរកំសាន្តដំបូងគេរបស់ប្រទេសជប៉ុនគឺ "ណាណាត្ស៊ឹបុស៊ិ (ផ្កាយប្រាំពីរ)" នៅគ្យូស្យ៊ូ បានបង្ហាញខ្លួននៅឆ្នាំ២០១៣។ រថភ្លើងដ៏ប្រណិតនេះបាននាំមកនូវការរួមគ្នាដ៏ល្អបំផុតនៃស្នាដៃសិប្បកម្មជប៉ុនផ្តល់ជូននៅពេលវាធ្វើដំណើរឆ្លងកាត់កោះគ្យូស្យ៊ូ។

តួរថភ្លើងត្រូវបានលាបពណ៌ស្រាក្រហម និងតុបតែងដោយនិមិត្តសញ្ញាមាសភ្លឺចិញ្ចាច។ រូបរាងដ៏ទាក់ទាញរបស់វាត្រូវបាននឹកឃើញដល់សណ្ឋាគារប្រណិតមួយ ដែល"ណាណាត្ស៊ឹបុស៊ិ (ផ្កាយប្រាំពីរ)" នៅគ្យូស្យ៊ូ គឺជារថភ្លើងសម្រាប់ភ្ញៀវទេសចរគេងបាន ជាមួយនឹងសេវាកម្មលំដាប់ថ្នាក់ទីមួយ ដែលធ្វើដំណើរជុំវិញកន្លែងល្បីៗនៅគ្យូស្យ៊ូមានទីតាំងនៅភាគនិរតីនៃប្រទេសជប៉ុន។

បន្ទប់ភ្ញៀវមានសភាពធំទូលាយដែលមានបង្អួចគយគន់ទេសភាពយ៉ាងធំ ហើយកន្លែងអង្គុយ ក៏មានកន្លែងទទួលភ្ញៀវផ្តល់នូវអារម្មណ៍នៃភាពកក់ក្តៅនៅក្នុងបរិយាកាសដ៏ទំនើបមួយ។ បរិយាកាសនេះពិតជាត្រូវបានបង្កើតឡើងដោយសម្ភារៈឈើដ៏ច្រើន ដែលបានប្រើប្រាស់នៅក្នុងទូរថភ្លើង។

ថ្វីត្បិតតែផ្នែកខាងក្នុងហាក់បីដូចជាធ្វើពីឈើទាំងស្រុងក៏ដោយ ការពិតគឺថាបច្ចេកទេសពិសេសត្រូវបានប្រើប្រាស់ដើម្បីធានាបានទាំងភាពរឹងមាំ ព្រមទាំងធន់នឹងភ្លើង។ ជញ្ជាំង និងពិដានអាចមើលទៅដូចជាឈើពេញ ប៉ុន្តែជាក់ស្តែងវាត្រូវបានធ្វើឡើងពីឈើធម្មជាតិមានកម្រាស់យ៉ាងស្តើងគឺ០.២មីលីម៉ែត្រ ស្រោបដោយអាលុយមីញ៉ូម។ ពិដានបន្ទះឈើ និងជញ្ជាំងតុបតែងសុទ្ធតែធ្វើពីឈើប្រណិតដែលបិតដោយដៃសិប្បករយ៉ាងយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបង្កើតឡើងវិញនូវវាយភាពឈើដែលមើលទៅធម្មជាតិគួរឱ្យភ្ញាក់ផ្អើល។

រថភ្លើង ណាណាត្ស៊ឹបុស៊ិ ក៏ត្រូវបានតុបតែងយ៉ាងស្រស់ស្អាតជាមួយនឹងគ្រឿងឈើប្រពៃណី អុកាវ៉ា គឹមិកុ ដែលជាបច្ចេកទេសមកពីទីក្រុងអុកាវ៉ា ក្នុងខេត្តហ្វឹគឹអុកា តំបន់គ្យូស្យ៊ូ ដែលត្រូវបានបន្តពីជំនាន់មួយទៅជំនាន់មួយ។

<u>ទំព័រទី១១៖</u>

បច្ចេកទេសសិប្បកម្មឈើគឹមិកុ គឺបង្ហាញពីលំនាំធរណីមាត្រដែលបង្កើតឡើងដោយការផ្គុំបំណែកឈើឱ្យមានរន្ធ និងប្រហោង។ សិល្បៈហត្ថកម្មដ៏អស្ចារ្យដែលធ្វើឱ្យមីក្រូន(ដុំឈើតូចៗ)ជាច្រើនបង្កើតបានជាការងារដ៏ស្រស់ស្អាត និងភាពរឹងមាំ។ អុការ៉ា គឹមិកុ តុបតែងជញ្ជាំង និងបង្អួចរថភ្លើង បង្ហាញពីគំរូ ឬ ម៉ូដដ៏ស្រស់ស្អាត តាមរយៈពន្លឺដ៏ស្រទន់ដែលជួយសម្រួលដល់ការសម្រាក និងបន្ធូរអារម្មណ៍របស់អ្នកដំណើរ។

បទពិសោធន៍សម្រាប់ខ្លួនអ្នកនូវការសម្រាកលំហែដ៏ស្ងប់ស្ងាត់បំផុត ដែលផ្តល់ជូនដោយឈើ និងស្វែងយល់ពីធម្មជាតិដ៏អស្ចារ្យ ព្រមទាំងទេសភាពដ៏ស្រស់ស្អាត។ វាពិតជា ដំណើរកម្សាន្តដែលគួរឱ្យសាកល្បងយ៉ាងហោចណាស់ម្តងក្នុងមួយជីវិតអ្នក។

*១. "ណាណាត្សឺបុសិ (ផ្កាយប្រាំពីរ)" នៅគ្យូស្យ៊ូ កំពុងរត់ក្នុងធម្មជាតិដ៏ខៀវស្រងាត់។*

*២. និមិត្តសញ្ញារថភ្លើងភ្លឺចិញ្ចាចដូចមាស។*

*៣. អ្នកដំណើរអាចសាកល្បងបង្កើត អុការ៉ា គឹមិកុ ពេលកំពុងជិះរថភ្លើង។*

*៤. អ្នកដំណើរក្នុងបន្ទប់ឌីលុច្ស (Deluxe) អាចរីករាយនឹងទិដ្ឋភាពដ៏អស្ចារ្យពីបង្អួចដ៏ធំនៃរថភ្លើង។*

*៥. កន្លែងទទួលភ្ញៀវ ជាកន្លែងសម្រាប់សម្រាកពេលរសៀល និងបារនៅពេលល្ងាច។*

*៦. ពន្លឺចាំងតាមជញ្ជាំង អុការ៉ា គឹមិកុ នាំមកនូវគំរូ ឬ ម៉ូដដ៏ស្រស់ស្អាត។*

<u>ទំព័រទី១២៖</u>

## សិប្បកម្មឈើ លាយបញ្ចូលគ្នារវាងសហសម័យ និងប្រពៃណី

សិប្បកម្មឈើសហសម័យនាំមកនូវភាពកក់ក្តៅនៃធម្មជាតិ និងរចនាបទនៃការរចនាដ៏អស្ចារ្យរួមគ្នាក្នុងការបង្កើតប្រពៃណី ដែលផ្សារភ្ជាប់គ្នាយ៉ាងរលូនដើម្បីប្រើប្រាស់ក្នុងការរស់នៅនាសម័យទំនើប។

**ពន្លឺដ៏ស្រទន់នៃបន្ទះឈើកោង**

អំពូលភ្លើងនេះមានការរចនាដ៏ស្មុគស្មាញនៃបន្ទះឈើកោងដែលបង្កើតដោយវត្ថុធាតុដើមធ្វើពីស្រទាប់ឈើសាគូរ៉ាបាញ់ថ្នាំលោងប៉ូលីប្រូភីលីន។ បន្ទះឈើរាងជាខ្សែកោង នាំឱ្យពន្លឺបញ្ចេញមកជាមួយស្រមោលដូចផ្កានៅលើពិដាន និងជញ្ជាំង។ (*រូបថតដោយ៖ តានិ តុស៊ិយ៉ឹគិ អ្នករចនាពន្លឺ*)

**កៅអីកាច់រាងលំដាប់ពិភពលោក**

កៅអីបញ្ឈរជារាងមេអំបៅ ធ្វើឡើងពីបន្ទះក្តារពីរសន្លឹកធ្វើជាទម្រង់កោង ដែលដូចកញ្ចក់ឆ្លាតបញ្ច្រាស់គ្នាឆ្វេង និងស្តាំ ដើម្បីបង្កើតជារូបរាងស្លាបមេអំបៅ។ ទម្រង់ច្នៃប្រឌិត និងសាមញ្ញនេះធ្វើឡើងដោយអ្នករចនា លោកយ៉ាណាហ្គិ សុរិ ដែលត្រូវបានកោតសរសើរទូទាំងពិភពលោក ហើយកៅអីរបស់លោក ក៏ជាសម្ភារៈមួយដែលត្រូវបានប្រមែប្រមូលទុកក្នុងសារមន្ទីរសិល្បៈដូចជា Louvre ផងដែរ ។ (*រូបថត៖* TENDO CO., LTD.)

<u>ទំព័រទី១៣៖</u>

**កៅអីមុខងារទ្វេដងអាចក្លាយជាកៅអីទោងសេះបោល**

<u>កៅអីសម្រាប់កុមារនេះ គឺមានភាពងាយស្រួល និងសុវត្ថិភាព។ កម្ពស់កែបកៅអីអាចផ្លាស់ប្តូរបានអាស្រ័យតាមការលូតលាស់របស់កុមារ ហើយការរចនារបស់វា ក៏អាចទ្រនឹងទម្ងន់មនុស្សពេញវ័យផងដែរ។ នៅពេលដែលត្រលប់ខាងវា នោះកៅអីនេះក្លាយជាកៅអីទោងសេះបោល ដែលកុមារចូលចិត្តជិះលេង។</u> (*រូបថត៖* Sdi Co., Ltd.)

**ស្តាប់សំឡេងតន្ត្រីបន្លឺចេញពីឈើ**

សិប្បកម្មឈើប្រពៃណីរបស់លោក ហ៊ិដា តាកាយ៉ាម៉ា នៅខេត្តហ្គីហ្វូ បាននាំយកមកនូវឧបករណ៍ស្តាប់ទំនើបចុងក្រោយសម្រាប់ការរស់នៅនាពេលបច្ចុប្បន្ន។ សំបកខាងក្រៅធ្វើពីបន្ទះឈើម៉ាប ដែលបញ្ចេញសំឡេងល្អ។ ស៊ុមរង្វង់ត្រចៀកធ្វើពីឈើហ៊ិណុគិ(ដើមស្រល់ហ៊ិណុគិ) ដើម្បីបង្កើតអារម្មណ៍ល្អចំពោះស្បែក។ (រូបថត៖ nokutare)

**ឈើប្រណិតដែលផលិតដោយវិធីសាស្រ្តផលិតដ៏គួរឱ្យកត់សម្គាល់**

"BUNACO" គឺជាម៉ាកផលិតផលដែលបង្កើតឡើងនៅអាអុម៉ុរិ ដែលមានភ្នំស៊ិរ៉ាកាមិ ជាព្រៃនៃដើមប៊ឹណា ដែលបានចុះបញ្ជីជាបេតិកភណ្ឌពិភពលោក។ ដើមប៊ឹណាច្នៃបានទៅជាបន្ទះក្តារដូចខ្សែបូ ដោយយកវាមករុំ បង្កើតបានជាចាន និងផុងផ្សេងៗជាច្រើនទៀត។ (*រូបថត៖* BUNACO)

**ការកែច្នៃប្រអប់បាយជប៉ុនបែបប្រពៃណីទៅជាទាន់សម័យ**

បច្ចេកទេស "ម៉ាហ្គិវ៉ាបប៉ា" នៃការពត់បន្ទះឈើហ៊ិណុគិ(ដើមស្រល់ហ៊ិណុគិ) និងស៊ីហ្គិ(ដើមតាត្រៅ)ទៅជារាងកោង ដែលភ្ជាប់ជាមួយសំបកដើមសាគូរ៉ា ឬ ដើមកាបា ដើម្បីផលិតបានប្រអប់បាយជាភាសាជប៉ុនហៅថា"បេនតូ" ដែលមានទម្ងន់ស្រាល ហើយរក្សាសំណើម និងការពារអាហារនៅខាងក្នុង។ រួមផ្សំជាមួយនឹងការរចនាដែលរំលេចពណ៌ ឬ ក្រយៅឈើ នាំឱ្យប្រអប់បាយទាំងនេះនៅតែបន្តមានប្រជាប្រិយភាពគ្រប់ជំនាន់។ (*រូបថត៖* PIXTA)

<u>ទំព័រទី១៤</u>៖

## ស្វែងយល់ពីក្លិនឈើ

"កូដូ" ដែលមានន័យថា "ពិធីមាគ៌ានៃក្លិនក្រអូប" ត្រូវបានប្រកាន់ខ្ជាប់នៅក្នុងប្រទេសជប៉ុន ដូចគ្នានិងពិធីលៀងតែ (សាដូ) និងសិល្បៈរៀបចំផ្កា(កាដូ)ជាដើមដែរ។ ឈើដើរតួនាទីយ៉ាងសំខាន់ក្នុងសិល្បៈដ៏ពិសេសនៃការលើកតម្កើងក្លិនក្រអូប។ (*កិច្ចសហប្រតិបត្តិការ និងរូបថត៖* Nippon Kodo Co., Ltd., Koju)

*រូបផ្នែកខាងលើ៖ គ្របដៃរបស់អ្នកស្រាលពីលើឧបករណ៍ដុតដើម្បី "ស្រង់ក្លិន" ក្រអូប។ កាយវិការដ៏ប្រណិតទាំងនេះគឺជាផ្នែកនៃក្បួនខ្នាតក្នុងពិធីកូដូ។* (*រូបថត៖* PIXTA)

*រូបខាងឆ្វេង៖ នៅក្នុងពិធីកូដូ ការរួមផ្សំនៃគ្រឿងក្រអូបប្រាំមួយប្រភេទត្រូវបានប្រើប្រាស់។*

*រូបខាងស្តាំ៖ ដើមចន្ទន៍ស(ប្យ៉ាគឹដាន) ជាឈើមានក្លិនក្រអូប។ ក្រៅពីធ្វើជាគ្រឿងក្រអូប វាក៏ត្រូវបានគេប្រើសម្រាប់ឆ្លាក់ព្រះពុទ្ធបដិមា និងធ្វើសិប្បកម្មផងដែរ។*

ដោយសារវប្បធម៌នៃក្លិនក្រអូបបានអភិវឌ្ឍនៅក្នុងប្រទេសជប៉ុន វាត្រូវបានផ្សារភ្ជាប់គ្នាដោយមិនអាចកាត់ថ្លៃបានជាមួយនឹងដើមឈើក្រអូប។ កូបុគឹ ជាភាសាជប៉ុនមានន័យថា "ឈើក្រអូប" ដែលត្រូវបានគេនិយាយថាបានមកដល់ប្រទេសជប៉ុនជាមួយនឹងការហូរចូលនៃព្រះពុទ្ធសាសនា ហើយវាត្រូវបានប្រើប្រាស់ដំបូងដើម្បីសម្អាតអាសនៈព្រះពុទ្ធសាសនា។ អំឡុងដើមសតវត្សទី៨ ក្នុងចំណោមពួកអភិជនបានចាប់ផ្តើមដុតក្លិនឈើក្រអូបដែលជាល្បាយនៃម្សៅក្រអូប និងគ្រឿងផ្សំក្រអូបផ្សេងៗទៀត ដើម្បីក្លិនបន្ទប់ និងសំលៀកបំពាក់របស់ពួកគេ។ ទម្លាប់នៃការដុតក្លិនឈើក្រអូប ក្រោយមកបានក្លាយជាការពេញនិយមក្នុងចំណោមពួកសាមូរ៉ៃ។ នៅទីបំផុត សិល្បៈដ៏ពិសេសនៃការលើកតម្កើងគ្រឿងក្រអូប បានក្លាយជា ពិធីកូដូ (ពិធីមាគ៌ានៃក្លិនក្រអូប) ក្នុងសតវត្សទី១៦។

ឈើក្រអូបដែលប្រើនៅក្នុងពិធីកូដូ ត្រូវបានបែងចែកជាពីរប្រភេទសំខាន់ៗ គឺដើមក្រស្នា(ជិនកូ) និងដើមចន្ទន៍ស (ប្យ៉ាគឹដាន)។ ដើមចន្ទន៍ស ជាប្រភេទអំបូរដើមខ្លឹមចន្ទន៍ ដែលមានក្លិនប្រហើរ ហើយត្រូវបានគេប្រើសម្រាប់វត្ថុទាក់ទងនឹងព្រះពុទ្ធសាសនា។ ចំណែកឈើក្រស្នា ជាពួកក្លាំពាក់ ដែលមានខ្លឹមនៅខាងក្នុងយ៉ាងអាថិកំបាំង អាចឃើញបាននៅពេលកាប់ ឬ ដើមដួលរលំ ហើយខ្លឹមរបស់វានឹងរឹងមាំយូរឆ្នាំ ហើយបញ្ចេញក្លិនក្រអូបនៅពេលត្រូវ

កំដៅ។ ថ្វីត្បិតតែក្លិនក្រអូបរបស់វាប្រែប្រួលពីដើមមួយទៅដើមឈើមួយក៏ដោយ ក៏ខ្លឹមក្រស្នាជាខ្លឹមឈើលំដាប់ខ្ពស់ ឬ ប្រណិត ហៅថា "ខ្យ៉ារ៉ា (ខ្លឹមចន្ទន៍ក្រស្នា)" ហើយវាមានតម្លៃខ្ពស់តាំងពីបុរាណកាលមក។

<u>ទំព័រទី១៥៖</u>

នៅក្នុងពិធីកូដូ គេកំដៅឈើក្រអូបនៅក្នុងឡដុតសេរ៉ាមិចតូចមួយ(ឧបករណ៍ដុតសម្រាប់ស្រង់ក្លិនក្រអូប) ដែលហៅថា "កូរ៉ុ" ហើយគេបានទទួលនូវអារម្មណ៍ពិដោរ ដែលត្រូវបានគេហៅថា "គិគឺ" (ន័យតាមពាក្យគឺ "ស្តាប់" តែបើន័យធៀបគឺ "ស្រង់ក្លិន")។ លក្ខណៈពិសេសនៃគន្ធពិដោរនីមួយៗ ត្រូវបានបង្ហាញនូវរសជាតិ "ផ្អែម" "ជូរ" ឬ "ល្វីង"។ នៅពេលដុតឈើក្រអូបជាច្រើនប្រភេទ ក្លិនក្រអូបចេញមកខុសគ្នា បង្កើតបានជាល្បែងកំសាន្តមួយដែលហៅថា "គឹមិកូ" ដែលអ្នកចូលរួមអាចទាយពីភាពខុសគ្នានៃក្លិនក្រអូប និងទំនាក់ទំនងជាមួយឃ្លាកំណាព្យជប៉ុន (វ៉ាកា ណុ គឺ)។ ល្បែងនេះ ត្រូវបានគេនិយាយថា ពិបាកខ្លាំងណាស់ក្នុងការទាយក្លិនក្រអូប ព្រោះគ្រាន់តែប្រែប្រួលបន្តិចបន្តួចនៃអាកាសធាតុ និងកម្រិតសំណើម ក្លិនក៏អាចផ្លាស់ប្តូរបានដែរ ប៉ុន្តែអ្វីដែលសំខាន់នៃល្បែងនេះ គឺមិនមែនការឈ្នះ ឬ ចាញ់នោះទេ។ ភាពរំភើបពិតប្រាកដនៃការលេងល្បែងនេះ គឺការរីករាយនៃការស្រង់ក្លិនក្រអូបចេញពីឈើក្រអូប ដែលធ្វើឱ្យអ្នកចូលរួមពង្រីកការស្រមើស្រមៃទៅកាន់ភាពរីករាយតាមរដូវកាល និងចំណង់ចំណូលចិត្តផ្នែកអក្សរសាស្ត្រ។

*១. កូរ៉ុ (ឡដុតសេរ៉ាមិចតូចទុកសម្រាប់ដុតឈើដើម្បីស្រង់ក្លិនក្រអូប) ដែលប្រើក្នុងពិធីកូដូ។ ឈើក្រអូបតូចមួយទំហំប្រហែល ២ម.ម រាងការ៉េ ត្រូវបានកំដៅនៅលើស្រទាប់ថ្មស្ពើងមិកា (រ៉ែ) ដាក់ពីលើផេះធ្យូង។*

*២. អ្នកចូលរួមប្រាប់ពីភាពខុសគ្នានៃក្លិនក្រអូប ដែលបានស្រង់ក្លិនក្រអូបឈើជាច្រើនប្រភេទជាល្បែងកំសាន្តមួយហៅថា គឹមិកូ។*

*៣. នៅពេលដែលអ្នកចំណាយពេលផ្តោតអារម្មណ៍ទៅលើក្លិនក្រអូប វាជាអ្វីដែលវាធ្វើឱ្យអ្នកមានភាពដូចគ្នាច្រើន ដូចទៅនឹងការធ្វើសមាធិ។*

**ភាពរីករាយនៃក្លិនជប៉ុន**

ក្លិនក្រអូបបែបបស្ចិមប្រទេសពាក់ព័ន្ធនឹងក្លិនក្រអូបពិសេសៗដូចជា ផ្កាកុលាប ផ្កាឡាវេនឌឺ និងជីអង្កាមជាដើម ដែលក្លិនក្រអូបទាំងនេះអ្នកស្គាល់ភ្លាមៗនៅពេលបានហិតវា។ ផ្ទុយទៅវិញ ក្លិនឈើក្រអូបគឺអរូបិយ ដែលក្លិនរបស់វាគឺបញ្ចេញតាមអារម្មណ៍ដែលមាននៅលើផែនដី។ ក្លិនមានឥទ្ធិពលទៅលើអារម្មណ៍ ឬ វិញ្ញាណទាំងប្រាំដូចជា ចក្ខុវិញ្ញាណ កាយវិញ្ញាណ ជីវ្ហាវិញ្ញាណ សោតវិញ្ញាណ ជាដើមក្នុងការពង្រឹងមុខងាររបស់រាងកាយ។

(ផ្អែកតាមការសន្ទនារបស់លោកអ៊ិណាហ្គាគិ យ៉ុស៊ិហ៊ិរ៉ុ "កូដូ")

*ក្នុងចំណោម "ខ្យាំវ៉ា (ខ្លឹមចន្ទន៍ក្រស្នា)" ដ៏ល្បីល្បាញបំផុតនៅក្នុងអត្ថិភាពគឺ "រ៉ានចាតៃ"។ វាត្រូវបានប្រគល់ទៅឱ្យ ស្យ៉ូសូអ៊ិន ដែលជាឃ្លាំងទ្រព្យសម្បត្តិរបស់ព្រះចៅអធិរាជនៃសតវត្សទី៨។ វាមានទម្ងន់ ១១.៦គីឡូក្រាម និងមានប្រវែង១៥៦សង់ទីម៉ែត្រ។*

<u>ទំព័រទី១៦៖</u>

## ដំណើរកំសាន្តនិម្មិតទូទាំងប្រទេសជប៉ុន៖ ដើមឈើជាមួយរឿងរ៉ាវនានា

នៅប្រទេសជប៉ុន ដើមឈើជាច្រើនត្រូវបានគេកត់សម្គាល់ និងគោរពស្រឡាញ់ ហើយដើមឈើបុរាណធំៗ ត្រូវបានគោរពបូជាដូចព្រះ ពីព្រោះដើមឈើត្រូវបានគេជឿថាមានវិញ្ញាណ។

**វត្តដាហ្សៃហ្វូ តិនម៉ានហ្គុ តុប៊ិអ៊ុមុិ (ខេត្តហ្វូគឹអ៊ុកា)**

រឿងព្រេងមួយបានដំណាលដូចតទៅ នៅពេលដែលសោកនាដកម្មនយោបាយ និងអក្សរសាស្ត្រ សង្កត់ធ្ងន់លើលោក ស៊ូហ្គាវ៉ារ៉ា មិឈិហ្សានិ (៨៤៥-៩០៣) ត្រូវបានបញ្ជូនពីក្យូតុ ទៅគ្យូស្យ៊ូ គាត់រំឮកនូវដើមផ្លែផ្លាំ ឬផ្លែអ៊ុមុិ ជាទីស្រឡាញ់ដែលគាត់បានបន្សល់ទុកនៅក្នុងកំណាព្យ បណ្តាលឱ្យដើមឈើហោះហើរទៅរកគាត់នៅគ្យូស្យ៊ូ។ ដើមតុប៊ិអ៊ុមុិ(មានន័យថា ផ្លាំហោះ) ឈរសំកាំងនៅខាងមុខវត្តដាហ្សៃហ្វូ តិនម៉ានហ្គុ ជាកន្លែងដែលមិឈិហ្សានិ ត្រូវបានតម្កល់ទុក។ នៅទីនេះ កំពុងមានផ្ការីកស្គុសស្គាយពេញនិទាឃរដូវ។ (រូបថត៖ PIXTA)

**ព្រៃព្រះវិហារកុបារ៉ា ជិនចា (គ្យាគឹ ជិនចា) (ខេត្តតុតុរី)**

ស្ងាត់ជ្រងំកណ្តាលវាលស្រែ ព្រៃដ៏តូចនេះ ចាប់យកការស្រមើស្រមៃដូចក្នុងឈុតឆាករបស់ស្ទូឌិយោហ្គិប្លិ គឺរឿង តុណារិ ណុ តុតុរ៉ុ (មានន័យថាអ្នកជិតខាង តុតុរ៉ុ)។ អ្វីដែលឈរថ្មឹងនៅទីនោះ តាមពិតគឺជាព្រះវិហារ ឬ ទីសក្ការៈតូចមួយ ហ៊ុំព័ទ្ធដោយដើមសុិអុិ(ដើមប៉ាសានៀ) ដើមម៉ុឈិណុគិ(ដើមហ្វលី) និងដើមឈើធំៗផ្សេងទៀត។ កន្លែងនេះបានក្លាយជាគោលដៅទេសចរដ៏ពេញនិយម បន្ទាប់ពីមានបង្ហាញនៅលើគេហទំព័រចូមក។ (រូបថត៖ Aflo)

**ដើមតាត្រៅ ចូម៉ូន ស៊ីហ្គិ នៅកោះយ៉ាគឹស៊ីម៉ា (ខេត្តខាហ្គុស៊ីម៉ា)**

ក្នុងចំណោមដើមតាត្រៅដែលដុះនៅកោះយ៉ាគឹស៊ីម៉ា "យ៉ាគឹស៊ីហ្គិ(ដើមតាត្រៅយ៉ាគឹ)" គឺជាដើមតាត្រៅដែលធំជាងគេ ហើយមានរូបរាងចំណាស់ជាងគេ ដែលត្រូវបានគេប៉ាន់ស្មានថា មានអាយុកាលចន្លោះពី២០០០ ទៅ៤០០០ឆ្នាំ ដែលមានរង្វង់ដើម១៦.៣ម និងរង្វង់ឫស៤៣ម។ ដើមឈើនេះ ត្រូវបានគេរំពឹងថា លូតលាស់ដើម្បីទប់ទល់នឹងខ្យល់ព្យុះទីហ្វុងញឹកញាប់ដែលបោកបក់មកលើកោះ។ វាត្រូវបានចុះបញ្ជីបេតិកភណ្ឌធម្មជាតិពិភពលោកនៅឆ្នាំ១៩៩៣។ (រូបថត៖ Takahira Yuuki)

**ដើមទេពិរូ (អូគីស៊ី) នៃ ផ្លូវធម្មយាត្រាចំណាស់គីម៉ាណុកុដូ ដៃម៉ុនហ្សាកា(ខេត្តវ៉ាកាយ៉ាម៉ា)**

គីម៉ាណុកុដូ ត្រូវបានចុះបញ្ជីជាតំបន់បេតិកភណ្ឌពិភពលោក ជាផ្លូវធម្មយាត្រាដែលត្រូវបានអ្នកធ្វើធម្មយាត្រារាប់មិនអស់តាំងពីបុរាណកាលមកអស់រយៈពេលជាងមួយពាន់ឆ្នាំមកហើយ។ ណាកាហិឈិ នៅលើភ្នំដែលមានរុក្ខជាតិដុះយ៉ាងខៀវស្រងាត់ផ្តល់នូវផ្លូវដ៏ពិសិដ្ឋ ហើយនៅច្រកចូលដៃម៉ុនហ្សាកា មានដើមទេពិរូ (អូគីស៊ី)យក្សដែលមានអាយុ៨០០ឆ្នាំឈរចាំស្វាគមន៍អ្នកធ្វើធម្មយាត្រា។ (រូបថត៖ PIXTA)

**ដើមផ្កាសាគូរ៉ា មិហារី តាគិហ្សាគីរ៉ា (ខេត្តហ្វូគូស៊ីម៉ា)**

មិហារី តាគិហ្សាគីរ៉ា (ដើមផ្កាសាគូរ៉ាទឹកជ្រោះ) ជាដើមឈើសម្រក់ទឹកភ្នែក អាយុកាលជាង១០០០ឆ្នាំ។ វាត្រូវបានគេហៅឈ្មោះបែបនេះ ដោយសារតែផ្កាដែលរីកស្គុសស្គាយពីដើមរបស់វាកម្ពស់១៣.៥ម៉ែត្រមើលទៅដូចជាទឹកជ្រោះ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដើមឈើបន្តពូជជាង៥០០ដើម ដែលមានអាយុលើសពី២០០ឆ្នាំត្រូវបានរកឃើញក្នុងចម្ងាយ១០គមនៃដើមឈើមេ ហើយកូនឈើជាច្រើនបានបន្តរីកដុះដាលពាសពេញពិភពលោក។ (រូបថត៖ PIXTA)

**ដើមឈើស្ត្រី (គុឈិហ្គិ)**

វាល អុដាស៊ិរ៉ុហ្គាហារ៉ា ជាតំបន់ដីសើមដែលបានចុះបញ្ជីនៅក្រោមអនុសញ្ញារ៉ាមសារ មានដើមស៊ិរ៉ាកានបាមួយដើមឈរ ដែលរូបរាងដ៏ប្រណិតរបស់វាបានទទួលឈ្មោះជាស្ត្រី។ ព្រៃដែលផ្លាស់ប្តូរពណ៌ទៅតាមរដូវកាល ដើរតួជាផ្ទៃខាងក្រោយដែលបំពេញបន្ថែមឱ្យដើមឈើស្ត្រីមើលទៅកាន់តែទាក់ទាញ ដែលស្វាគមន៍អ្នកមកទស្សនាម្តងហើយម្តងទៀតមិនឱ្យធុញទ្រាន់។ (រូបថត៖ Aflo)

**ដើមស្រល់ខ្មៅ យ៉ូហ្គូណុម៉ាត្ស៊ឺ ក្នុងវត្តហ្សេនយ៉ុជិ (តូក្យូ)**

ដើមស្រល់ខ្មៅជប៉ុនដែលមានអាយុជាង៦០០ឆ្នាំ ហៅថា យ៉ូហ្គូណុម៉ាត្ស៊ឺមានកម្ពស់៨ម ប៉ុន្តែមែកវាបានលាតសន្ធឹងពីប៉ែកខាងកើតទៅខាងលិចប្រហែល៣១ម និងខាងជើងទៅខាងត្បូងប្រហែល២៨ម។ ដើមឈើបង្ហាញពីទេសភាពដែលសមនឹងឈ្មោះរបស់វា យ៉ូហ្គូ (ដែលមានន័យថា «ព្រះ ឬ ព្រះពុទ្ធបង្ហាញខ្លួន»។ (រូបថត៖ PIXTA)

**វាលស្រល់ប៉ៃតង មិហុ ណុ ម៉ាត្ស៊ឺបារ៉ា (ខេត្តស៊្ស៊ីហ្ស៊ឺអុកា)**

កន្លែងដែលមានទេសភាពដ៏អស្ចារ្យនៃខ្សាច់ពណ៌ស និងដើមស្រល់បៃតង ត្រូវបានចុះឈ្មោះជាផ្នែកមួយនៃភ្នំហ្វូជិដែលជាតំបន់បេតិកភណ្ឌវប្បធម៌ពិភពលោក។ រឿងព្រេងនិទានដ៏ល្បីល្បាញរបស់អ្នកនេសាទដែលបានរកឃើញ

អាវស្បៃរោមសត្វបក្សីមួយរបស់ទេពធិតាឋានសួគ៌ដែលបានព្យួរលើដើមឈើនៅវាលស្រល់បៃតង (មិហុ ណុ ម៉ាត់ស៊ឹបារ៉ា) ហើយបុរសនេសាទបានស្នើសុំទេពធិតានោះរាំជាថ្នូរនឹងការប្រគល់អាវជូនវិញ ហើយវាក៏ក្លាយជាសាច់រឿងនៃការសម្តែងល្ខោនណូហ៍។ (រូបថត៖ បណ្ណាល័យរូបថត)

**ជិនហ្គឺ ប៊ីរិន (ខេត្តហ៊ីហ្វូ)**

ព្រះវិហារអ៊ិសិ ជិនហ្គឺ នៅខេត្តមិអិ គឺជាទីសក្ការៈសំខាន់ជាងគេទាំងអស់នៅប្រទេសជប៉ុន។ នៅលើភ្នំនៃតំបន់ហ៊ីហ្វូ មានព្រៃធម្មជាតិនៃដើមឈើស្រល់ហ៊ិណុគិ ដែលត្រូវបានប្រើប្រាស់សម្រាប់ពិធីបុណ្យ"ស៊ិគិណេន សេនហ្គឺ" ដែលជាពិធីបុណ្យសាងសង់ទីសក្ការបូជាឡើងវិញរៀងរាល់២០ឆ្នាំម្តង។ ព្រៃដើមស្រល់ហ៊ិណុគិត្រូវបានដាំដុះដោយគ្មានការអន្តរាគមន៍ពីមនុស្ស និងទៅតាមពេលវេលា វាបានលូតលាស់ឡើងយ៉ាងរឹងមាំ និងស្រស់ស្អាត។ (រូបថត៖ ការិយាល័យគ្រប់គ្រងព្រៃឈើ តូណូ)

<u>ទំព័រទី១៨៖</u>

## រសជាតិជប៉ុន ៖ ពេលវេលាទទួលទាន! ផ្សិតម៉ាត់ស៊ឹតាក㉑

**ផ្សិតម៉ាត់ស៊ឹតាកិ**

កាដូដ៏ឈ្ងុយឈ្ងប់ពីព្រៃ

រូបថត៖ Arai Akiko

**(ពិពណ៌នារូបថត) ផ្សិតម៉ាត់ស៊ឹតាកិអាំង**

*ប្រសិនបើអ្នកចង់រីករាយជាមួយនឹងរសជាតិដ៏ឈ្ងុយឆ្ងាញ់នៃផ្សិតម៉ាត់ស៊ឹតាកិ វិធីដ៏ល្អបំផុត គឺការអាំងទាំងមូល។ ពេលនៅស្រស់ ផ្សិតទាំងនេះ មានផ្ទុកនូវជាតិសំណើមច្រើន ដូច្នេះការខាំទំពារមួយម៉ាត់ៗ នឹងផ្តល់នូវក្លិនឈ្ងុយ និងរសជាតិឆ្ងាញ់ឥតគណនា។*

ម៉ាត់ស៊ឹតាកិ គឺជាផ្សិតម្យ៉ាងដែលដុះនៅគល់ដើមឈើអំបូរស្រល់។ នៅជប៉ុន ជាទូទៅ យើងអាចរកវាបាននៅក្នុងព្រៃដើមស្រល់ក្រហម(អាកាម៉ាត់ស៊ឹ)ជប៉ុន។ ផ្សិតជាច្រើនប្រភេទជាទីពេញនិយមនៅតុអាហាររបស់ជនជាតិជប៉ុន ប៉ុន្តែនៅពេលនិយាយអំពី "ផ្សិតពិសេស" សម្រាប់ប្រជាជនជប៉ុន គ្មានអ្វីពិសេសជាងផ្សិតម៉ាត់ស៊ឹតាកិនេះទេ។

ភាពទាក់ទាញដ៏អស្ចារ្យបំផុតរបស់ផ្សិតម៉ាត់ស៊ឹតាកិ គឺក្លិនផ្អែមប្លែករបស់វា ដែលមានពីសារធាតុអ៊ុកទេណុល ឬក្លិនប្រេងផ្សិតហ្នឹងតែម្តង។ ម៉ាត់ស៊ឹតាកិ គឺជាស្តេចម្ហូបក្នុងរដូវស្លឹកឈើជ្រុះ ដូច្នេះប្រជាជនជប៉ុនទាំងអស់ដែលឱ្យតម្លៃអាហារផ្តោតទៅលើក្លិនជាចម្បង តែងសង្ឃឹមថា នឹងបានភ្លក់រសជាតិនេះយ៉ាងហោចណាស់បានម្តង មុនរដូវរងារ

ចូលមកដល់។ ដោយសារតែ ម៉ាត្សឹតាកិ អាចបាត់បង់នូវភាពស្រស់របស់វាយ៉ាងឆាប់រហ័ស និងមិនអាចដាំដុះបាន ដោយសិប្បនិម្មិត ព្រមទាំងតម្រូវការច្រើន ដូច្នេះវាមានតម្លៃថ្លៃណាស់។

ផ្សិតម៉ាត្សឹតាកិនេះ មានតម្លៃថ្លៃតាំងពីបរមបុរាណមកម្ល៉េះ ហើយត្រូវបានជាប់ចំណាត់ថ្នាក់ក្នុងចំណោមវត្ថុដ៏មាន តម្លៃសម្រាប់ថ្វាយដល់ព្រះចៅអធិរាជ ដែលបានកត់ត្រាក្នុងសៀវភៅប្រវត្តិសាស្ត្រសតវត្សរ៍ទី៨។ កំឡុងសម័យ អេដូ (១៦០៣-១៨៦៨) ប្រជាជនសឹងតែត្រូវបង់ពន្ធលើផ្សិតម៉ាត្សឹតាកិ។ អ្នកភូមិ ត្រូវបានត្រួតត្រាយ៉ាងតឹងរ៉ឹងលើ ការប្រមូលផលផ្សិតម៉ាត្សឹតាកិ ដូចជាមិនអនុញ្ញាតិទិញលក់ផ្សិតនេះដោយគ្មានការអនុញ្ញាតិ ទោះបីជាម្ចាស់ដី ដែលមានផ្សិតនេះដុះដោយឯកឯងក៏ដោយ។

ការផ្លាស់ប្តូរបរិស្ថានព្រៃសព្វថ្ងៃនេះ មានឥទ្ធិពលលើការប្រមូលផលផ្សិតម៉ាត្សឹតាកិ។ ដើមស្រល់ក្រហមជប៉ុន ដែលជាផ្ទះនៃផ្សិតម៉ាត្សឹតាកិ ត្រូវបានគេប្រើប្រាស់ជាអុស និងធ្យូងនៅជប៉ុនជាយូរមកហើយ។ ដោយហេតុផល នេះ ព្រៃស្រល់ក្រហមទាំងនេះ ត្រូវបានមនុស្សថែរក្សាជាប្រចាំ ដែលបង្កើតបានជាបរិយាកាសសមរម្យមួយ សម្រាប់ផ្សិតម៉ាត្សឹតាកិ ដែលត្រូវការតំបន់ដែលមានពន្លឺថ្ងៃគ្រប់គ្រាន់ និងខ្យល់ចេញចូលបានល្អ។ ចាប់ពីទសវត្សរ៍ ឆ្នាំ១៩៧០មក នៅពេលដែលប្រេងត្រូវបានក្លាយជាជម្រើសក្នុងការប្រើប្រាស់របស់មនុស្ស ព្រៃស្រល់ក្លាយជាមិន ត្រូវបានថែទាំ ដែលជាមូលហេតុនាំឱ្យមានការថយចុះទិន្នផលផ្សិតម៉ាត្សឹតាកិ។

នៅក្នុងម្ហូបអាហារជប៉ុន ផ្សិតម៉ាត្សឹតាកិ ត្រូវបានអាំង ឬចម្អិនជាមួយបាយយ៉ាងសាមញ្ញ ដើម្បីកុំឱ្យបាត់បង់នូវក្លិន និងឱជារសយ៉ាងពិសេសរបស់វា។ លោក មិយ៉ាណាមិ យឹហ្សឹរី ម្ចាស់ភោជនីយដ្ឋាន "អាកាសាកាម៉ាត្សឹបាយ៉ា" ឯកទេសខាងផ្សិតម៉ាត្សឹតាកិ នៅតំបន់អាកាសាកា ទីក្រុងតូក្យូ បានប្រាប់ដដែលៗថា វាមានសារសំខាន់ណាស់ក្នុង ការរក្សាផ្សិតម៉ាត្សឹតាកិឱ្យនៅស្រស់។ លោកអះអាងថា «ពេលវេលាកាន់តែយូរ ផ្សិតកាន់តែបាត់បង់ក្លិន និង ភាពស្រស់របស់វា ប៉ុន្តែជាមួយនឹងការដឹកជញ្ជូនទំនើបបច្ចុប្បន្ននេះ ផ្សិតម៉ាត្សឹតាកិ បានមកដល់ទីតាំងក្នុងសភាព ស្រស់ៗ ដែលនេះជាការប្រសើរខ្លាំងណាស់។»

លោក មិយ៉ាណាមិ ធ្លាប់ជាអ្នកលក់បោះដុំផ្សិតម៉ាត្សឹតាកិទៅកាន់ទីផ្សារ បានប្រាប់លាយឡំនឹងសំណើចថា «នៅពេលធ្វើការជាមួយនឹងផ្សិតម៉ាត្សឹតាកិពេញមួយថ្ងៃ ធ្វើឱ្យជាប់ក្លិនផ្សិតម៉ាត្សឹតាកិតាំងពីក្បាលដល់ចុងជើង។» វាច្បាស់ណាស់ថា ដោយសារក្លិនខ្លាំងបែបនេះហើយ គឺជាភាពទាក់ទាញនៃផ្សិតម៉ាត្សឹតាកិ។

ប្រទេសជប៉ុនប្រហែល២ភាគ៣ បានរីករាយនឹងអំណោយផលធម្មជាតិជាច្រើនពីក្នុងព្រៃ។ ចំណុចកំពូលនៃ អំណោយផលពីព្រៃឈើទាំងនោះគឺ ផ្សិតម៉ាត្សឹតាកិ។ ហើយភាពកម្ររបស់ផ្សិតនេះ នាំឱ្យប្រជាជនជប៉ុន កាន់តែ ចូលចិត្តវា។

ទំព័រទី១៩៖

*ដុប៊ីន មឹស៊ិ (ស៊ុបចំហុយក្នុងឆ្នាំងដី)*

*ដុប៊ីន មឹស៊ិ ត្រូវបានធ្វើឡើងពីគ្រឿងផ្សំ ដូចជា ផ្សិតម៉ាត្ស៊ឹតាកិ បង្គា និងគ្រឿងផ្សំដទៃទៀត ចំហុយជាមួយនឹងទឹកស៊ុបដាស៊ិ ក្នុងឆ្នាំងដីតូចមួយហៅថា ដុប៊ីន។ អ្នកនឹងរីករាយទទួលទានស៊ុបដាស៊ិ ដ៏មានឱជារសដែលចម្រាញ់ចេញពីរសជាតិរសជាតិអ៊ុម៉ាមិ និងក្លិនឈ្ងុយឈ្ងប់នៃផ្សិត។ ហើយបន្ថែមនូវទឹកក្រូចឆ្មា (ក្រូចលឿងជប៉ុនហៅថា ស៊ឺដាឈិ) ដើម្បីជម្រុញរសជាតិ អ៊ុម៉ាមិ។*

*រូបខាងលើ៖ ផ្សិតម៉ាត្ស៊ឹតាកិ រាងឆត្របិទ ឬមួកបិទជិត ត្រូវបានចាត់ទុកថា មានក្លិនច្រើនជាងគេ ដូច្នេះរាងបែបនេះគឺពេញនិយមជាងគេ។*

*រូបខាងក្រោម៖ ភោជនីយដ្ឋាន អាកាសាកាម៉ាត្ស៊ឹបាយ៉ា ជាភោជនីយដ្ឋានដែលមានឯកទេសខាងផ្សិតម៉ាត្ស៊ឹតាកិ និងសាច់គោជប៉ុន ហ៊ិដា ដែលបានទិញចូល និងបម្រើជូននូវផ្សិតម៉ាត្ស៊ឹតាកិគុណភាពខ្ពស់។*

*ម៉ាត្ស៊ឹតាកិ ហ្គូហាន់(បាយផ្សិតម៉ាត្ស៊ឹតាកិ)*

*ផ្សិតម៉ាត្ស៊ឹតាកិ និងបាយ ត្រូវបានចម្អិនលាយគ្នាយ៉ាងសាមញ្ញ ជាមួយទឹកស៊ុប និងទឹកស៊ីអ៊ីវ។ ហាន់ផ្សិតជាចំនិតស្តើងៗ ប៉ុន្តែត្រូវប្រាកដថា រក្សារូបរាងដើមរបស់ផ្សិត។ យើងអាចរីករាយនឹងការបញ្ចូលគ្នានៃអង្ករស្រូវថ្មី (ស៊ិនម៉ៃ) និងផ្សិតម៉ាត្ស៊ឹតាកិបានតែនៅរដូវស្លឹកឈើជ្រុះតែប៉ុណ្ណោះ។*

ទំព័រទី២០៖

## ដើរកំសាន្តប្រទេសជប៉ុន៖ ម៉ាត្ស៊ឹម៉ុតុ

ទីក្រុងសិប្បកម្មនៅជើងភ្នំព្រិលភាគខាងជើងប្រទេសជប៉ុន

ព័ទ្ធជុំវិញទៅដោយភ្នំ ពេលវេលារំកិលទៅមុខសន្សឹមៗដោយស្ងៀមស្ងាត់ ខ្យល់អាកាសបរិសុទ្ធនៃទីក្រុងម៉ាត្ស៊ឹម៉ុតុ ទីក្រុងជាមួយពេលវេលារប្បធមិដ៏មានតម្លៃនៃសិល្បៈហត្ថកម្ម។ (រូបថត៖ អូសាកា សាតុស៊្សឺ Aflo និងPIXTA

ទំព័រទី២១៖

*១.(រូបធំខាងលើ) ប្រាសាទម៉ាត្ស៊ឹម៉ុតុ ដែលមានកម្ពស់៣០ម។ នៅថ្ងៃដែលមេឃស្រលះល្អ កន្លែងនេះ ផ្តល់នូវទេសភាពដ៏ស្រស់ស្អាតជាមួយជួរភ្នំព្រិលភាគខាងជើងជាទេសភាពផ្ទៃខាងក្រោយ។*

*២. (រូបស្ដាំខាងលើ) មួយក្នុងចំណោមរមណីយដ្ឋានតំបន់ភ្នំឈានមុខគេរបស់ជប៉ុនគឺ កាមិកុឈិ ដែលចំណាយពេលប្រហែល៦០នាទីដោយរថយន្តក្រុងពីកណ្ដាលក្រុងម៉ាត្សឹម៉ុតុ។ នៅទីនោះ ការធ្វើចរាចរដោយរថយន្តផ្ទាល់ខ្លួនត្រូវបានហាមឃាត់ ដើម្បីការពារបរិស្ថានធម្មជាតិ។*

*៣. (រូបស្ដាំកណ្ដាល) អតីតសាលាកាអ៊ិឈិ បានបើកជាសាលាបឋមសិក្សា នៅចុងសតវត្សរ៍ទី១៩ ។ អគារសិក្សាដែលបានកសាងក្នុងឆ្នាំ១៨៧៦ ត្រូវបានប្រើប្រាស់រហូតដល់ឆ្នាំ១៩៦៣។ (រូបថតផ្ដល់ដោយ៖ ក្រុមប្រឹក្សាអប់រំទីក្រុងម៉ាត្សឹម៉ុតុ; អគារនេះត្រូវបានបិទរហូតដល់រដូវស្លឹកឈើជ្រុះ ឆ្នាំ២០២៤ ដោយសារការកែទម្រង់ឡើងវិញដើម្បីធន់នឹងការរញ្ជួយដី)*

*៤. (រូបស្ដាំខាងក្រោម) ការដាក់តាំងសិល្បៈដោយ លោកស្រី គឹសាម៉ា យ៉ាយ៉ុអ៊ិ ស្វាគមន៍អ្នកទស្សនាមកសារមន្ទីរសិល្បៈទីក្រុងម៉ាត្សឹម៉ុតុ។ (រូបថតផ្ដល់ដោយ៖ សារមន្ទីរសិល្បៈទីក្រុងម៉ាត្សឹម៉ុតុ)*

<u>ទំព័រទី២២៖</u>

*៥. "បន្ទប់តាំងគ្រឿងសង្ហារិមដោយដៃសិប្បករតំបន់ម៉ាត្សឹម៉ុតុ" មានតាំង និងលក់ គ្រឿងសង្ហារិមបែបប្រពៃណីម៉ាត្សឹម៉ុតជាច្រើនប្រភេទ។ កៅអី ដែលត្រូវបានធ្វើឡើងតាមលំនាំការរចនារបស់អង់គ្លេសក្លាយជានិមិត្តសញ្ញានៃគ្រឿងសង្ហារិមសិប្បកម្មប្រជាប្រិយម៉ាត្សឹម៉ុតុ។*

*៦. គ្រឿងសង្ហារិមទាំងអស់ត្រូវបានធ្វើឡើងដោយដៃទាំងស្រុង សូម្បីតែឧបករណ៍ដែលប្រើប្រាស់ក៏ត្រូវធ្វើឡើងដោយដៃសិប្បករដែរ។*

ត្រឹមតែពីរម៉ោងកន្លះពីកណ្ដាលទីក្រុងតូក្យូដោយរថភ្លើងល្បឿនកំណត់(តុកគ្យឺរេស្សា) អ្នកអាចមើលឃើញទិដ្ឋភាពដ៏ស្រស់ស្អាតនៃភ្នំព្រិលភាគខាងជើងនៃប្រទេសជប៉ុនពីបង្អួចរថភ្លើង។ ម៉ាត្សឹម៉ុតុ ខេត្តណាហ្គាណុ មានទីតាំងនៅកណ្ដាលនៃប្រជុំកោះជប៉ុន ជាតំបន់ដែលហ៊ុមព័ទ្ធជុំវិញដោយភ្នំនៅគ្រប់ទិសទី ដែលរួមមានកាមិកុឈិ ដែលល្បីល្បាញដោយសារទេសភាពភ្នំដ៏ស្រស់ស្អាត។ ជាមួយនឹងទន្លេដែលហូរកាត់កណ្ដាលទីក្រុង ហើយមានប្រភពទឹកជាច្រើនដែលចេញពីក្រោមដីហូរពីភ្នំ និងអណ្ដូងមានពាសពេញទីក្រុង។ បរិស្ថានធម្មជាតិដ៏សម្បូរបែបនេះ ផ្ដល់ឱ្យទីក្រុងនូវខ្យល់អាកាសបរិសុទ្ធ។

ប្រាសាទម៉ាត្សឹម៉ុតុ ដែលជាកំណប់ទ្រព្យជាតិ ត្រូវបានសាងសង់ឡើងនៅចុងសតវត្សទី១៦ ដែលឈរជានិមិត្តរូបនៃប្រវត្តិសាស្ត្រដ៏យូរអង្វែងរបស់ទីក្រុងនៃភាពរុងរឿង គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទីតាំងងាយស្រួលសម្រាប់ការដឹកជញ្ជូនទំនិញ។ លក្ខណៈពិសេសរបស់វា គឺប្រាសាទកម្ពស់ប្រាំជាន់ដែលមានអាយុកាលចំណាស់ជាងគេនៅក្នុងប្រទេសជប៉ុន និងជាកន្លែងដ៏អស្ចារ្យដែលទាក់ចិត្តដោយសម្រស់យ៉ាងស្រស់ស្អាតនៃរដូវកាលទាំងបួន រួមជាមួយនឹងគូទឹកដែលព័ទ្ធជុំវិញ។ នៅខាងជើងប្រាសាទ មានអតីតអគារសាលាកាអ៊ិឈិ ដែលបានសាងសង់នៅពាក់កណ្ដាលចុងសតវត្សរ៍ទី១៩។ ទីតាំងប្រវត្តិសាស្ត្រដ៏សំខាន់នេះ ត្រូវបានសាងសង់ដោយជាងឈើក្នុងស្រុក ដែលមានលក្ខណៈចម្រុះរវាងស្ថាបត្យកម្មជប៉ុន និងលោកខាងលិច និងរំឭកពីសម័យកាលទំនើបកម្មរបស់ប្រទេសជប៉ុន។

*៧. ពិព័រណ៌សិប្បកម្មម៉ាត្ស៊ឹម៉ុតុ បានចាប់ផ្តើមនៅឆ្នាំ១៩៨៥ ដែលទាក់ទាញភ្ញៀវមកទស្សនាមិនត្រឹមតែការតាំងពិព័រណ៌ឈើប៉ុណ្ណោះទេ ថែមទាំងគ្រឿងស្មូន សិប្បកម្មកញ្ចក់ និងវាយនភណ្ឌផងដែរ។ (រូបថតផ្តល់ដោយៈ សមាគមសិប្បកម្មម៉ាត្ស៊ឹម៉ុតុ)*

*៨. "ហ្គាលើរៀ កាអ៊ិហ្គិស៊ី" មានទំនិញជាច្រើនប្រភេទផ្សេងៗដែលប្រមូលផ្តុំមកពីតំបន់ក្នុងស្រុក និងទូទាំងប្រទេសជប៉ុន។ ខាងស្តាំៈ ផលិតផលស្តង់ដារនៃហាងគឺ ពែងស្រាធ្វើពីឈើប៊ូលូនៀ លាបម្រ័ក្សណ៍ខ្មុកដែលមានទម្ងន់ស្រាល ងាយស្រួលប្រើប្រចាំថ្ងៃ។ ខាងឆ្វេងៈ កាបូប ផលិតដោយសិប្បករក្នុងស្រុក ដែលមានសាច់ក្រណាត់ល្អ និងការជ្រលក់ពណ៌យ៉ាងស្រស់ស្អាតដ៏ពេញនិយម។*

<u>ទំព័រទី២៣</u>ៈ

*៩. "កុហ៊ិរីដូ" គឺជាភោជនីយដ្ឋានដ៏ពេញនិយមដែលបន្ថែមភាពទាន់សម័យផ្ទាល់ខ្លួនទៅនឹង ប្រពៃណីអុយ៉ាគិ។ វាជាកន្លែងដ៏ល្អមួយដើម្បីរីករាយនំអុយ៉ាគិ ជាមួយជ្រក់ណុហ្សាវ៉ាណា ដែលជាអាហារពិសេសរបស់ភោជនីយដ្ឋាន ឬជាមួយឈីស ផ្លែប៉ោម និងគ្រឿងផ្សំជាច្រើនទៀត។*

*១០. ខៃអឺនដូ ហាងបង្អែមប្រពៃណីមួយដែលបានបង្កើតឡើងជាយូរមកហើយ មានអាយុកាលតាំងពីឆ្នាំ១៨៨៤។ បង្អែមប្រចាំហាងគឺ ស៊ិនមិតុ ជាបង្អែមជប៉ុនធ្វើពីស្ករ ទឹកឃ្មុំ និងគ្រាប់ធញ្ញជាតិ (walnut)។*

*១១. "កាហ្វេម៉ារីម៉ុ ឬ គិសសាម៉ារីម៉ុ" គឺជាហាងកាហ្វេ ដែលផ្នែកខាងក្នុងត្រូវបានរចនាឡើងដោយមានជំនួយពីស្ថាបនិកគ្រឿងសង្ហារិមសិប្បកម្មប្រជាប្រិយម៉ាត្ស៊ឹម៉ុតុ។ អតិថិជនជាច្រើនគាំទ្រនូវការកិន និងឆុងគ្រាប់កាហ្វេសុទ្ធ ព្រមទាំងនំគុកឌីងធ្វើផ្ទាល់ដៃក្នុងហាង។*

ម៉ាត្ស៊ឹម៉ុតុដែលមានអំណោយផលនឹងឈើដែលមានគុណភាពខ្ពស់ នាំឱ្យឧស្សាហកម្មផលិតគ្រឿងសង្ហារិមនៅទីនេះមានការរីកចម្រើនតាំងពីសម័យអេដូ (១៦០៣-១៨៦៨)។ ទោះបីជាឧស្សាហកម្មធ្លាក់ចុះមួយរយៈ ប៉ុន្តែវាមានការរស់ឡើងវិញក្នុងទស្សវត្សរ៍ឆ្នាំ១៩៤០ ក្រោមឥទ្ធិពលនៃចលនាសិប្បកម្មប្រជាប្រិយជប៉ុន(មីនហ្គេអ៊ីនដូ) ដែលព្យាយាមថែរក្សា និងផ្ទេរបន្តនូវបច្ចេកទេសសិប្បកម្មនៃវត្ថុប្រើប្រាស់ប្រចាំថ្ងៃ។ គ្រឿងសង្ហារិមសិប្បកម្មប្រជាប្រិយម៉ាត្ស៊ឹម៉ុតុ បានកើតមកដោយរួមបញ្ចូលនូវសំណង់ដ៏សាមញ្ញ និងភាពរឹងមាំរបស់គ្រឿងសង្ហារិមជប៉ុន ជាមួយរូបភាពរាងកោងនៃគ្រឿងសង្ហារិមលោកខាងលិច។ ពន្លឺពណ៌ត្នោតក្រហមដែលបង្ហាញដោយការលាបវ៉ានីស និងម្រ័ក្សណ៍ខ្មុកយ៉ាងប្រុងប្រយ័ត្នលើឈើសាគូរ៉ាជប៉ុន(មិហ្សុមិហ្សាគូរ៉ា) នៅតែជាទីពេញចិត្តរបស់ប្រជាជនជប៉ុនសព្វថ្ងៃ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ម៉ាត្ស៊ឹម៉ុតុ ក៏ត្រូវបានគេស្គាល់ផងដែរថាជាទីក្រុងនៃសិល្បៈ និងសិប្បកម្ម។ សារមន្ទីរសិល្បៈទីក្រុងម៉ាត្ស៊ឹម៉ុតុ ដែលមានការតាំងពិព័រណ៌អចិន្ត្រៃយ៍នៃស្នាដៃ Avant-garde ក្នុងស្រុករបស់សិល្បករ គឺសាម៉ា យ៉ាយ៉ុអ៊ិ ដែលនេះជាឧទាហរណ៍ដ៏សំខាន់មួយ។ ផ្សារពិព័រណ៌សិប្បកម្មម៉ាត្ស៊ឹម៉ុតុ ដែលប្រារព្ធឡើងជារៀងរាល់ឆ្នាំក្នុងខែឧសភានោះ ជាទីទាក់ទាញដល់អ្នកសិល្បៈគ្រឿងស្មូន ជាងឈើ និងអ្នកចូលចិត្តសិប្បកម្មពីទូទាំងប្រទេសជប៉ុន ហើយឥឡូវនេះបានក្លាយជាទីកន្លែងមិនអាចខ្វះបាននារដូវកាលនៃរុក្ខជាតិបៃតងស្រស់។ ម៉ាត្ស៊ឹម៉ុតុ ក៏ជាកន្លែងរបស់វិចិត្រសាលឯករាជ្យជាច្រើន និងមានហាងលក់ទំនិញផ្សេងៗដ៏ទំនើបដែល

ដំណើរការដោយម្ចាស់ដែលមានជំនាញច្បាស់លាស់នៅក្នុងទីក្រុង ដូច្នេះត្រូវប្រាកដថាអ្នកនឹងស្វែងរកស្នាដៃដែលត្រូវនឹងចំណង់ចំណូលចិត្តរបស់អ្នក។

ពេលឃ្លាន សូមសាកល្បង អុយ៉ាគិ ដែលជានំប្រពៃណីក្នុងស្រុក ធ្វើពីម្សៅស្រូវសាលីខ្ចប់ស្នូលដែលមានលាយជាមួយគ្រឿងផ្សំពីបន្លែ ឬផ្លែឈើ ហើយអាំង ឬដុតវា។ ការឈប់នៅក្នុងហាងនំដែលមានអាយុចំណាស់ក្នុងទីក្រុង និងដើរទេសចរណ៍ ឬ ជ្រើសរើសវត្ថុអនុស្សាវរីយ៍ ក៏ជាពេលដ៏រីករាយមួយដើម្បីបន្លប់ពេលវេលាផងដែរ។ ប្រសិនបើរួយជើងនឿយហត់ហើយ អ្នកអាចចំណាយពេលសម្រាកនៅ "កាហ្វេម៉ារឹម៉ុ" ជាហាងកាហ្វេមួយដែលមានការតុបតែងប្រកបដោយបរិយាកាសរំឭកដល់អតីតកាល ដែលមានតុ និងកៅអីគ្រឿងសង្ហារិមបែបប្រពៃណីសិប្បកម្មប្រជាប្រិយម៉ាត្សឹម៉ុតុ។ ម៉ាត្សឹម៉ុតុ រក្សារូបរាងនៃទីក្រុងប្រាសាទប្រវត្តិសាស្ត្រ ប៉ុន្តែមិនធ្វើឱ្យអ្នកមានអារម្មណ៍ថាចាស់នោះទេ។ អ្នកទស្សនាប្រាកដជារីករាយនឹងភាពទាក់ទាញពិសេសនៃការលាយបញ្ចូលគ្នានៃវប្បធម៌សិប្បកម្មប្រពៃណី និងសហសម័យរបស់វា ក្នុងបរិយាកាសធម្មជាតិដ៏សម្បូរបែប។

*ផែនទីតំបន់ម៉ាត្សឹម៉ុតុ (សូមមើលរូប)*

*១. ប្រាសាទម៉ាត្សឹម៉ុតុ*

*២. អតីតសាលាកាអ៊ិឈិ*

*៣. សារមន្ទីរសិល្បៈនៃទីក្រុងម៉ាត្សឹម៉ុតុ*

*៤. មជ្ឈមណ្ឌលតាំងបង្ហាញគ្រឿងសង្ហារិមសិប្បកម្មប្រជាប្រិយម៉ាត្សឹម៉ុតុ*

*៥. ហ្គាលើរី កាអ៊ិហ្គិស៊ឹ*

*៦. កុហ៊ិរីដូ*

*៧. ខៃអឹនដូ*

*៨. កាហ្វេម៉ារឹម៉ុ ឬ គិសសាម៉ារឹម៉ុ*

*. មធ្យោបាយធ្វើដំណើរ៖ ពីស្ថានីយរថភ្លើង ស៊ីនជឹគឹ ទៅស្ថានីយរថភ្លើង ម៉ាត្សឹម៉ុតុ ប្រហែល២ម៉ោងកន្លះ តាមរយៈរថភ្លើងល្បឿន JR Chuo Line*

*. ទំនាក់ទំនងព័ត៌មាន សូមចូលទៅកាន់គេហទំព័រ ម៉ាត្សឹម៉ុតុ*

*សេចក្តីណែនាំអំពីការធ្វើដំណើរជាផ្លូវការរបស់ម៉ាត្សឹម៉ូតុ ខេត្តណាហ្គាណូ ប្រទេសជប៉ុន*

https://visitmatsumoto.com/

<u>ទំព័រទី២៤</u>៖ **វត្ថុអនុស្សាវរីយ៍របស់ជប៉ុន៖** ㉓

*រូបភាពដោយ ម៉ាត្សឹស៊ិតា ជិរ៉ុ*

**ភាពស្រស់ស្អាតបន្ថែមសោភណ៍ភាពជីវិត**

# កន្ត្រកឫស្សី

ដើមឫស្សីដុះលូតលាស់បានលឿន ដោយសារតែសមត្ថភាពរបស់វាក្នុងការទប់ទល់នឹងភាពត្រជាក់ និងរក្សាបាននូវពណ៌បៃតង វាត្រូវបានគេចាត់ទុកថាជាវត្ថុសំណាងមួយរួមជាមួយនឹងដើមស្រល់(ម៉ាត្ស៊ឹ) និងដើមផ្លាំ(អ៊ុម៉ិ) ដែលតាំងពីបុរាណកាលមក វាត្រូវបានប្រើប្រាស់ក្នុងគំនូរ និងសិប្បកម្មជប៉ុន។ ម្យ៉ាងវិញទៀត កន្ត្រកត្បាញពីបន្ទះឫស្សីដ៏វិចិត្រ ឬហៅថា ហ៊ិហ្គោ បានក្លាយជាសម្ភារៈផ្សេងៗ និងមានប្រយោជន៍ក្នុងចំការ និងផ្ទះបាយ ហើយក៏ជាជំនួយដ៏ល្អសម្រាប់ប្រជាជនជប៉ុនដែលធ្វើការក្នុងផ្ទះបាយ និងចំការផងដែរ។

សព្វថ្ងៃនេះ មនុស្សកាន់តែច្រើន កំពុងនាំយករបស់ប្រើប្រាស់ទាំងនេះ ដូចជាកន្ត្រកឫស្សីត្រឡប់មកក្នុងជីវិតរបស់ពួកគេវិញហើយ។ មិនត្រឹមតែការអនុវត្តជាក់ស្តែងប៉ុណ្ណោះទេ ភាពកក់ក្តៅដែលធ្វើដោយដៃរបស់ពួកគេ និងការរចនាគួរឱ្យចាប់អារម្មណ៍ធ្វើឱ្យវាមានចំណុចពិសេសរៀងៗខ្លួន។ ទីកន្លែង មុខងារ រូបរាង និងរបៀបប្រើប្រាស់វា គឺអាស្រ័យលើគំនិតរបស់អ្នក។ "បង្ហាញចំណុចទាក់ទាញកន្ត្រក" ដោយដាក់វាតំរៀបគ្នា ឬប្រើដៃអ្នកកាន់កន្ត្រកសម្រាប់ជាការរចនាដែលធ្វើឱ្យសោភណ័ភាពរបស់វាកើនទ្វេដង។ អ្នកអាចប្រើប្រាស់កន្ត្រកជាថាសសម្រាប់ដាក់កែវ ចាន ឬមួយកាន់យួរវាដើរនារដូវក្តៅ ដែលបង្កើតជារូបភាពទាន់សម័យគួរជាទីទាក់ចិត្ត។

ភាពទាក់ទាញនៃកន្ត្រកឫស្សីរបស់ជប៉ុនត្រូវបានរកឃើញនៅក្នុងភាពខុសគ្នាជាច្រើននៃលំនាំក្រឡាតម្បាញដ៏អស្ចារ្យ។ ស្វែងរកកន្ត្រកឫស្សីសំណព្វចិត្តរបស់អ្នកនៅហាងឯកទេស ឬហាងនានានៅប្រទេសជប៉ុនដែលអ្នកបានទៅកំសាន្ត។ អ្នកប្រាកដជានឹងស្រឡាញ់វាដូចជាកំណប់ទ្រព្យ។

*ផ្នែកឆ្វេងខាងលើៈ ពន្លឺឆ្លងកាត់លើកន្ត្រកឫស្សីពណ៌បៃតង ធ្វើឱ្យមើលទៅទូលាយ និងមានអារម្មណ៍ត្រជាក់។*

*ផ្នែកឆ្វេងខាងក្រោមៈ កន្ត្រកប្រើដើម្បីដាក់ទឹកស៊ីអ៊ីវ និងគ្រឿងទេសផ្សេងទៀតទៅកាន់តុអាហារ។*

*ផ្នែកស្តាំខាងលើៈ គ្រាន់តែដាក់ក្រណាត់បត់ពីលើកន្ត្រក បង្កើតបានជាវត្ថុមួយដ៏ស្រស់ស្អាត។*

*ផ្នែកស្តាំខាងក្រោមៈ កន្ត្រកអាជិរ៉ុអាមិ ដែលត្បាញដោយបន្ទះឫស្សីជាក្រឡាបញ្ឆិត(រូបឆ្វេង) និង កន្ត្រកស៊ឹកាស៊ិអាមិ ដែលត្បាញជាក្រឡារាងទឹករលក។*

*ទស្សនាវដ្ដី "និប៉ុនិកា" លេខ៣២*
*បោះពុម្ពផ្សាយដោយក្រសួងការបរទេសជប៉ុន*
*២-២-១ កាស៊ុមិហ្គាសិគិ សង្កាត់ជិយ៉ូដា ទីក្រុងតូក្យូ ១០០-៨៩១៩ ប្រទេសជប៉ុន*
*គេហទំព័រផ្លូវការរបស់ក្រសួង* https://www.mofa.go.jp/
*គេហទំព័រដែលផ្ដល់ព័ត៌មានអំពីជប៉ុន* https://web-japan.org/